# ការជូនដំណឹងដល់អ្នកទទួល CALFRESH (កាលពីមុនហៅថាបណ្ណជំនួយម្ហូបអាហារ) ទាំងអស់ពី WINS (អត្ថប្រយោជន៍អាហារបំប៉នអាហារូបត្ថម្ភជាការលើកទឹកចិត្តការងារ)

# សំខាន់ – សូមអាន

WINS គឺជាកម្មវិធីផ្តល់អត្ថប្រយោជន៍អាហារបំប៉ន $10 ក្នុងមួយខែមួយសម្រាប់គ្រួសារបុគ្គលិកសង្គមកិច្ច ដែលកំពុងទទួលអត្ថប្រយោជន៍ CalFresh តែពុំមែនកំពុងទទួលអត្ថប្រយោជន៍ពី CalWORKs (កម្មវិធីឱកាសការងារនិងទំនួលខុសត្រូវចំពោះកុមារនៃរដ្ឋកាលីហ្វញ៉ា) ឬកម្មវិធីជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រខ្សត់ (TANF) នៃក្រុមកុលសម្ព័ន្ធ។

ច្បាប់រដ្ឋកាលីហ្វញ៉ាចែងដូចខាងក្រោម៖

- គ្រួសារ CalFresh ដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃចំនួនម៉ោងធ្វើការសម្រាប់ WINS តែពុំមែនកំពុងទទួលបានអត្ថប្រយោជន៍ CalWORKs ឬ TANF របស់ក្រុមកុលសម្ព័ន្ធទេ អាចមានសិទ្ធិទទួលអត្ថប្រយោជន៍អាហារ $10 ក្នុងមួយខែបន្ថែមបាន។
  - លក្ខខណ្ឌតម្រូវនៃចំនួនម៉ោងធ្វើការគឺ៖
  - 20 ម៉ោងក្នុងមួយសប្តាហ៍សម្រាប់គ្រួសារមានឪពុកម្តាយ/អាណាព្យាបាលតែម្នាក់ជាមួយនឹងកូនក្រោមអាយុប្រាំមួយឆ្នាំយ៉ាងហោចមួយ
  - 30 ម៉ោងក្នុងមួយសប្តាហ៍សម្រាប់គ្រួសារមានតែឪពុក ឬម្តាយ/អាណាព្យាបាលតែម្នាក់ជាមួយកូនអាយុចន្លោះប្រាំមួយទៅដប់ប្រាំបីឆ្នាំ
  - 35 ម៉ោងក្នុងមួយសប្តាហ៍សម្រាប់គ្រួសារមានឪពុកនិងម្តាយ/អាណាព្យាបាលពីរនាក់។

ការងារដែលរាប់បញ្ចូលគឺជាការងារដែលរកប្រាក់កម្រៃបានទាំងឡាយ (សូម្បីបើបានទទួលឧបត្ថម្ភធនដូចជារៀនផងធ្វើការផងក្តី)។
នេះក៏រួមបញ្ចូលការងារបម្រើការឱ្យខ្លួនឯងផងដែរ។

- គ្រួសាររបស់អ្នកអាចនឹងមានសិទ្ធិ ប្រសិនបើអ្នក៖
  - ជាគ្រួសារ CalFresh មួយ តែពុំមែនកំពុងទទួលអត្ថប្រយោជន៍ CalWORKs ឬ TANF នៃក្រុមកុលសម្ព័ន្ធ ហើយ
  - មានកូនក្រោមអាយុ 18 ឆ្នាំមួយនៅផ្ទះ ព្រមទាំង
  - មានឪពុកម្តាយ/អាណាព្យាបាលយ៉ាងហោចម្នាក់នៅក្នុងគ្រួសារដែលបំពេញតាមនិយមន័យនៃ "បុគ្គលមានសិទ្ធិធ្វើការ" របស់ TANF ហើយកំពុងតែមានចំនួនម៉ោងធ្វើការគ្រប់គ្រាន់ ដូចបានរាយខាងលើក្នុងសកម្មភាពការងារដែលបំពេញតាមលក្ខខណ្ឌតម្រូវ TANF សហព័ន្ធ
- ការផ្តល់ប្រាក់ប្រចាំខែនេះនឹងបន្តរៀងរហូត ឱ្យតែអ្នកបំពេញតាមលក្ខខណ្ឌតម្រូវនៃកម្មវិធី WINS។
- អត្ថប្រយោជន៍ $10 ជាអត្ថប្រយោជន៍អាហារមួយ ហើយពុំអាចប្រើជាសាច់ប្រាក់ឡើយ។
- ប្រសិនបើអ្នកចង់ដឹងបន្ថែម សូមទាក់ទងបុគ្គលិកសង្គមកិច្ចរបស់អ្នក។

គ្រួសារដែលមានសិទ្ធិទទួល CalFresh នីមួយៗអាចទទួលបានតែអត្ថប្រយោជន៍ WINS មួយប៉ុណ្ណោះក្នុងមួយខែ។ អត្ថប្រយោជន៍នឹងត្រូវចែកចាយលើបណ្ណផ្ទេរអត្ថប្រយោជន៍អេឡិកត្រូនិក (EBT) មានស្រាប់របស់គ្រួសារ ជាអាហារបំប៉នបន្ថែមទៅលើផលចំណែក CalFresh របស់គ្រួសារ។ ការមានសិទ្ធិទទួលអត្ថប្រយោជន៍ WINS ត្រូវបានកំណត់នៅពេលអ្នកដាក់ពាក្យសុំ រាយការណ៍ពីការផ្លាស់ប្តូរនានា ឬសុំអត្ថប្រយោជន៍បន្ត។ បើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី WINS អត្ថប្រយោជន៍នេះនឹងត្រូវបន្ថែមចូលបណ្ណ EBT របស់អ្នក។

សូមប្រាកដថា ត្រូវរាយការណ៍ចំនួនម៉ោងការងាររបស់អ្នកទៅកាន់បុគ្គលិកសង្គមកិច្ចកំណត់សិទ្ធិទទួលអត្ថប្រយោជន៍របស់អ្នក នៅពេលអ្នកដាក់ពាក្យសុំ CalFresh ជាលើកដំបូង នៅពេលអ្នកត្រូវតែតម្រូវឱ្យរាយការណ៍ពីការផ្លាស់ប្តូរនានា ឬនៅពេលអ្នកសុំអត្ថប្រយោជន៍ CalFresh បន្ត ដើម្បីឱ្យពួកគេអាចកំណត់ថាអ្នកមានសិទ្ធិទទួលឬទេ។

ប្រសិនបើអ្នកគិតថា យើងមានកំហុសក្នុងការសម្រេចពីអត្ថប្រយោជន៍ CalFresh របស់អ្នក ដោយសារតែអត្ថប្រយោជន៍ WINS ថ្មី អ្នកអាចស្នើសុំឱ្យមានសវនាការរដ្ឋមួយ***ក្នុងពេល 90 ថ្ងៃ ចាប់ពីពេលដែលអ្នកបានទទួលលិខិតនេះ ដោយសរសេរទៅកាន់៖***

មិនដូច្នោះទេ អ្នកអាចទូរស័ព្ទដោយឥតគិតថ្លៃ៖ 1-800-952-5253។ ប្រសិនបើអ្នកថ្លង់ ហើយប្រើ TDD សូមទូរស័ព្ទទៅលេខ 1-800-952-8349។ នៅពេលអ្នកស្នើសុំសវនាការរដ្ឋ អ្នកត្រូវតែប្រាប់យើងពីមូលហេតុដែលអ្នកគិតថា យើងបានធ្វើខុស។ អ្នកអាចនិយាយការពារខ្លួននៅក្នុងសវនាការបាន ឬក៏អ្នកអាចឱ្យមិត្តភក្តិ មេធាវី ឬបុគ្គលផ្សេងទៀតនិយាយតំណាងអ្នកបាន តែអ្នកត្រូវតែឱ្យអ្នកទាំងនេះជួយដល់អ្នក។ អ្នកអាចស្នើសុំជំនួយផ្លូវច្បាប់ដោយឥតគិតថ្លៃនៅការិយាល័យជំនួយផ្លូវច្បាប់ក្នុងតំបន់របស់អ្នក